ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧៤៥...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩

# ប្រកាស

## ស្ដីពី

## ការកែសម្រួលសមាសភាពគណៈដឹកនាំក្រុមប្រតិបត្តិសំរាប់អនុវត្ត « យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ »

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨ /១០៥៤ ចុះ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨ /១០៥៥ ចុះ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ខែ សីហា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្ដីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- **បានឃើញឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧**
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ២៤៨ សហវ. ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ-៩៤១ សហវ.ឧហ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីការបង្កើតក្រុមប្រតិបត្តិប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការកែសម្រួល និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ២៨៦ សហវ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការតែងតាំង និងផ្លាស់ប្ដូរសមាជិកក្រុមប្រតិបត្តិប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ១៤៧ សហវ.ឧហ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០៦ ស្ដីពីការផ្លាស់ប្ដូរសមាជិកក្រុមប្រតិបត្តិប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ៩១១ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៧ ស្ដីពីការកែសម្រួលសមាជិកក្រុមប្រតិបត្តិប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ១៥៥៥ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ស្ដីពីការទទួលស្គាល់ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ១០៧ សហវ.ប្រកប ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ ស្ដីពីការទទួលស្គាល់ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ។

## សំរេច

**ប្រការ ១** : កែសម្រួលសមាសភាពក្រុមប្រតិបត្តិ ( Task Force ) ប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងប្រចាំក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥ ( Financial Sector Development Strategy 2006-2015 ) ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១- លោក **ម៉ី ទ៉ាន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក **ខុង ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | អនុប្រធាន |

**- ការិយាល័យគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និងហិរញ្ញប្បទានសំរាប់សហគ្រាសធុនតូច និងមធ្យម**

| | | |
|---|---|---|
| ៣- លោក **ឌុច សុតិរិទ្ធ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៤- លោក **អ៊ុត មុន្នី** | មន្ត្រីការិយាល័យគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និង SMEs | សមាជិក |
| ៥- លោក **ឆេត សុភក្រ្ត** | មន្ត្រីការិយាល័យគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និង SMEs | សមាជិក |

**- ការិយាល័យទីផ្សារហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ៦- លោក **នីម ចន្ធា** | ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ | សមាជិក |
| ៧- លោក **ហ៊ុយ ទ៉ាំថារ៉ូ** | មន្ត្រីការិយាល័យទីផ្សារហិរញ្ញវត្ថុ | សមាជិក |
| ៨- លោក **នីម និដ្ឋានុ** | មន្ត្រីការិយាល័យទីផ្សារហិរញ្ញវត្ថុ | សមាជិក |

**- ការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ**

| | | |
|---|---|---|
| ៩- លោក **ម៉ៅ ពៅ** | អនុប្រធានការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ | សមាជិក |
| ១០- លោក **គុយ តារា** | អនុប្រធានការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ | សមាជិក |
| ១១- លោក **ឆេត ម៉ុន្នារិទ្ធិ** | មន្ត្រីការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ | សមាជិក |

១២- លោក ខៅ ដាវីឌុន មន្ត្រីការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ សមាជិក
១៣- លោក អ៊ុយ រិទ្ធីមុនី មន្ត្រីការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ សមាជិក

**- ការិយាល័យធានារ៉ាប់រង**

១៤- លោក អ៊ិន មារុត្រា ប្រធានការិយាល័យធានារ៉ាប់រង សមាជិក
១៥- លោក ម៉ោក ចាន់ត្រា អនុប្រធានការិយាល័យធានារ៉ាប់រង សមាជិក

**- ក្រុមប្រឹក្សាជាតិគណនេយ្យ**

១៦- លោក ចូ ចារិន លេខាធិការរងក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក
១៧- លោក ឡាយ ម៉ិនចា លេខាធិការរងក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក
១៨- លោក ជា ចាន់ថា ប្រធានការិយាល័យក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក
១៩- លោកស្រី គឹមស្រួរ សុធីរ៉ា ប្រធានការិយាល័យក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក
២០- លោក សេង សុផា មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក

**ប្រការ ២ :** ក្រុមប្រតិបត្តិនេះ មានភារកិច្ចអនុវត្តគំរោងប្រចាំថ្ងៃដែលពាក់ព័ន្ធទៅនឹងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥ តាមការណែនាំរបស់ប្រធានក្រុមប្រតិបត្តិដែលជាសមាជិកនៃក្រុមការងារបច្ចេកទេស ។

**ប្រការ ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជា**

**ប្រធាន[illegible]គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ចំលងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
« ដើម្បីជូនជ្រាប »
- ដូចប្រការ ៤
« ដើម្បីអនុវត្ត »
- ឯកសារ- កាលប្បវត្តិ